ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## កិច្ចសន្ទនាតាមទូរស័ព្ទរវាង ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម ប៊ូយ ថាញ់សឺន រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២១

--------

នៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២១ **ឯកឧត្តម** ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានជួបសន្ទនាតាមទូរស័ព្ទជាមួយ **ឯកឧត្តម ប៊ូយ ថាញ់សឺន** ដើម្បីអបអរសាទរដែលឯកឧត្តមត្រូវបានតែងតាំងជា រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នាពេលថ្មីៗនេះ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរប្រទេសវៀតណាមដែលទទួលបានជោគជ័យក្នុងការរៀបចំមហាសន្និបាតបក្សកុម្មុយនិស្តវៀតណាមលើកទី១៣ និងសម័យប្រជុំទី១១ នីតិកាលទី១៤ នៃរដ្ឋសភាវៀតណាម ការធ្វើជាប្រធានអាស៊ានឆ្នាំ២០២០ និងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP)។ **ឯកឧត្តម** ក៏បានសម្តែងនូវជំនឿជឿជាក់ផងដែរថា ជាមួយនឹងបទពិសោធន៍ការទូត និងជំនាញដ៏ទូលំទូលាយរបស់ **ឯកឧត្តម ប៊ូយ ថាញ់សឺន** ប្រទេសវៀតណាម នឹងដើរតួនាទីកាន់តែសំខាន់ឡើងនៅក្នុងកិច្ចការតំបន់ និងអន្តរជាតិ។

ជាការឆ្លើយតប **ឯកឧត្តម ប៊ូយ ថាញ់សឺន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម ប្រាក់ សុខុន** សម្រាប់សារអបអរសាទរ និងសារធុការពរ ដែលជាការលើកទឹកចិត្តសម្រាប់**ឯកឧត្តម** ក្នុងការបំពេញភារកិច្ចថ្មី។

ក្នុងអំឡុងកិច្ចសន្ទនាតាមទូរស័ព្ទ រដ្ឋមន្ត្រីការបរទេសទាំងពីរបានពិភាក្សាដោយស្មោះត្រង់ និងភាតរភាព អំពីទំនាក់ទំនងទ្វេភាគី និងបានសម្តែងនូវការពេញចិត្តចំពោះការកើនឡើងជាលំដាប់នូវចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរនៅលើវិស័យជាច្រើន រួមមាន វិស័យអប់រំ ពាណិជ្ជកម្ម វិនិយោគ ថាមពល ការតភ្ជាប់ និងសន្តិសុខ ស្របពេលជាមួយការផ្ទុះឡើងនូវជំងឺកូវីដ-១៩។ រដ្ឋមន្ត្រីការបរទេសទាំងពីរក៏បានសម្តែងនូវការប្តេជ្ញាចិត្តរឹងមាំ ក្នុងការធ្វើការជាមួយគ្នា

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh